01149750

Declassified to Public
12 June 2020



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 28-Sep-2015, 10:48
CMS/CFO: Sann Rada

ការិយាល័យសហចៅក្រមស៊ើបអង្កេត

Office of the Co-Investigating Judges
Bureau des co-juges d'instruction

**សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក -ក.ស.ច.ស**

ចំពោះមុខ ៖ **សហចៅក្រមស៊ើបអង្កេត**

កាលបរិច្ឆេទ ៖ **ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១៥**

ភាសា ៖ **អង់គ្លេស [ភាសាដើម]**

ចំណាត់ថ្នាក់ឯកសារ ៖ **សម្ងាត់**

---

# ដីកាលើដីកាសម្រេចលើការដាក់បញ្ចូលឯកសារនៅក្នុងសំណុំរឿង០០៤ ពីខែ កក្កដា និងខែ សីហា ឆ្នាំ ២០១៥

---

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា** **អង្គជំនុំជម្រះសាលាដំបូង**

ជា លាង

Nicholas KOUMJIAN

**I. ប្រវត្តិនីតិវិធី**

១. នៅថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៥ ព្រះមហាក្សត្រ នរោត្តម សីហមុនី បានឡាយព្រះហស្ថលេខាលើលិខិតតែងតាំងខ្ញុំជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិដោយចូលជាធរមានភ្លាមៗ។ ចៅក្រម Harmon និងខ្ញុំ ទើបតែបានទទួលដំណឹងជាផ្លូវការអំពីការតែងតាំងខ្ញុំ នៅថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៥។

២. រវាងថ្ងៃទី ៣១ ខែ កក្កដា និងថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៥ ចៅក្រម Harmon បានចេញដីកាសម្រេចចំនួនបួនលើការដាក់បង្ហាញឯកសារនៅក្នុងសំណុំរឿង ០០៤។ ដីកាសម្រេចទាំងនេះមានដូចខាងក្រោម៖

(ក) *ដីកាសម្រេចផ្នែកខ្លះលើសំណើ D193/29 របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារ* ចេញនៅថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៥ ("D193/30")។

(ខ) *ដីកាសម្រេចលើសំណើ D167, D193/7, D193/17, D193/31 និង D193/32 របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារសម្រាប់សំណុំរឿង ០០២* ចេញនៅថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៥ ("D193/33")។

(គ) *ដីកាសម្រេចលើសំណើ D193/23 និង D193/29 របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារ* ចេញនៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៥ ("D193/34")។

(ឃ) *ដីកាសម្រេចលើសំណើបន្ទាន់ D193/36 របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារ* ចេញនៅថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៥ ("D193/37")។

**II. ពិភាក្សា**

៣. នៅពេលដែល ចៅក្រម Harmon ចេញដីកាសម្រេចលើការដាក់បង្ហាញឯកសារដូចបានបង្ហាញខាងលើនៅក្នុងកថាខណ្ឌ ២ គាត់ ដូចជា ខ្ញុំ ដែរ មិនបានដឹងថា នៅថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៥ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា បានឡាយព្រះហស្ថលេខាលើការតែងតាំងខ្ញុំ ជំនួសចៅក្រម Harmon ទេ។ ដោយសារមានការតែងតាំងនេះ អាណត្តិការងាររបស់ចៅក្រម Harmon បានបញ្ចប់ ហើយសិទ្ធិអំណាចរបស់គាត់ក្នុងការបំពេញកិច្ច

01149752



ក្នុងសមាសភាពជាអំណាចតុលាការ ក៏បានបញ្ចប់ដែរ។

៤. ដូច្នេះ ចៅក្រម Harmon លែងមានសិទ្ធិអំណាចនៅពេលនោះ ហើយដីកាសម្រេចចំនួនបួនលើការដាក់បង្ហាញឯកសារ មិនមានសុពលភាពទេ ទោះបីជាថា គាត់បានបំពេញកិច្ចដោយសុទ្ធចិត្តសុទ្ធសាធក៏ដោយ។ ដោយសារថា គ្រាន់តែដាក់បង្ហាញឯកសារពីសំណុំរឿងមួយទៀត មិនមែនជាកិច្ចស៊ើបសួរទេ ទើប បទប្បញ្ញត្តិនៃវិធានផ្ទៃក្នុង ៧៦ មិនអនុវត្តទេ។

៥. ខ្ញុំបានត្រួតពិនិត្យមើលសេចក្តីសម្រេចនានារបស់ចៅក្រម Harmon ហើយយល់ស្របតាមសេចក្តីសម្រេចទាំងនោះ។ ហេតុដូច្នេះ ខ្ញុំប្រកាន់យកសេចក្តីសម្រេចរបស់ចៅក្រម Harmon ហើយចេញសាឡើងវិញដីកាសម្រេចទាំងបួនគឺ D193/30, D193/33, D193/34 និង D193/37។

៦. ខ្ញុំកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូង បច្ចុប្បន្ននេះកំពុងទទួលពិនិត្យមើលសំណើរបស់ ខៀវ សំផន នៅក្នុងសំណុំរឿង ០០២/០២("សំណើ")[1] ដែលតវ៉ាថា សហព្រះរាជអាជ្ញា មិនគោរពតាមកាតព្វកិច្ចរបស់ខ្លួនក្នុងការដាក់បង្ហាញឯកសារទេ ដែលសំណើនេះសហព្រះរាជអាជ្ញា បានដាក់ចម្លើយតបរួចហើយ[2]។ ខណៈដែល ខ្ញុំ យល់ និងគាំទ្រលក្ខណៈនៃសេចក្តីព្រួយបារម្ភដែលមេធាវីការពារក្តី ខៀវ សំផន បានលើកឡើងនៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួននៅក្នុងសំណើយ៉ាងណាក៏ដោយ ក៏ នេះគឺជាកិច្ចការរបស់អង្គជំនុំជម្រះសាលាដំបូង មិនមែន ស.ច.ស ទេ ដែលជាអ្នកកំណត់អំពីផលប៉ះពាល់នៃឯកសារដែលបានដាក់បង្ហាញមកលើសិទ្ធិរបស់ជនជាប់ចោទនៅក្នុងសំណុំរឿង ០០២/០២។ ហេតុដូច្នេះ ខ្ញុំនឹងបន្តទទួលសំណើសុំដាក់បង្ហាញឯកសារបន្ថែមទៀត និងសម្រេចលើសំណើទាំងនោះ ដោយផ្អែកលើភាពពាក់ព័ន្ធជាបឋម និងផលប៉ះពាល់ដែលសំណើទាំងនោះអាចមានមកលើភាពសម្ងាត់ និងសុចរិតភាពនៃកិច្ចស៊ើបសួរ ។

---

[1]សំណុំរឿង ០០២ ឯកសារ E363 *សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី លោក ខៀវ សំផន ពាក់ព័ន្ធនឹងកាតព្វកិច្ចដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញា* ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៥។

[2]សំណុំរឿង ០០២ ឯកសារ E363/1 *ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសេចក្តីសន្និដ្ឋានរបស់ ខៀវ សំផន ទាក់ទងនឹងកាតព្វកិច្ចរបស់សហព្រះរាជអាជ្ញាក្នុងការដាក់បង្ហាញឯកសារ* ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០១៥។

**តាមសំអាងហេតុខាងលើ ខ្ញុំ ៖**

៧. **ចេញសាឡើងវិញ**ដីកាសម្រេចលើការដាក់បង្ហាញឯកសារគឺ D193/30, D193/33, D193/34 និង D193/37 តាមខ្លឹមសារទាំងស្រុង។

ភ្នំពេញ ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១៥

**ចៅក្រម Michael Bohlander**

**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**

**International Co- Investigating Judge**
**Co-juge d'instruction International**